# តើអ្នកពូកែអ្វី?

# What are you good at?

Written by TukTuk

Illustrated by Choven Hen

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C






សូមស្កេនQR Code

គំនូរជីវចល

ធនធានបង្រៀន

Written by TukTuk

Illustrated by Choven Hen

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



នារសៀលថ្ងៃមួយ យ៉េកកំពុងដឹកខេទីនិងលោកគ្រូសុខនៅលើរ៉ឺម៉កកង់បីរបស់គាត់ ដើម្បីជិះដើរលេង។ ស្រាប់តែពួកគាត់បាន ប្រទះឃើញរតនានិងមករាកំពុងលេងនៅតាមផ្លូវ។

ខេទីក៏ស្រែកសួរ « តើអ្នកទាំងពីរចង់ឡើងមកជិះរ៉ឺម៉កកង់បី ដើរលេងជាមួយពួកយើងដែរឬទេ? »

ឮដូចនេះ កុមារទាំងពីរនាក់សប្បាយត្រេកអរយ៉ាងខ្លាំង ហើយក៏ហក់ឡើងរ៉ឺម៉កកង់បី ជាមួយពួកគេតែម្តង។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C




ខណៈពេលដែលពួកគាត់ទាំងអស់គ្នា កំពុងជិះរ៉ឺម៉កកង់បីដើរលេង ស្រាប់តែរតនាប្រាប់យ៉េកនិងខេទី
« ខ្ញុំពូកែគណិតណាស់។ ថ្ងៃនេះ ថ្នាក់របស់ខ្ញុំប្រឡង ហើយខ្ញុំបានលេខមួយទៀតហ៎! »




មករាក៏និយាយ « ឯខ្ញុំវិញពូកែភាសាខ្មែរ ខាងប្រកបពាក្យខ្លាំងណាស់។
ថ្ងៃនេះ ថ្នាក់របស់ខ្ញុំក៏ប្រឡងដែរ ហើយខ្ញុំប្រកបត្រូវគ្រប់ពាក្យ។ ចុះយ៉េកវិញពូកែខាងអ្វីដែរ? »

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



យ៉េកឆ្លើយ « ខ្ញុំខ្ពស់ ហើយខ្ញុំអាចឈោងដៃដល់កន្លែងខ្ពស់ៗជាច្រើន »



លោកគ្រូសុខក៏ឆ្លើយដែរ « លោកគ្រូវិញមានកម្លាំងខ្លាំង។ លោកគ្រូអាចលើករបស់ធ្ងន់ៗបានជាច្រើន »

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



ចំណែកឯ ខេទីវិញនៅស្ងៀម។

« ចុះខេទីវិញ? តើអ្នកពូកែខាងអ្វីដែរ? »

ខេទីគិតមួយសន្ទុះ រួចក៏សម្រេចចិត្តឆ្លើយទាំងទឹកមុខស្រពាប់ស្រពោន « ខ្ញុំគិតថា ខ្ញុំដូចជាអត់មានពូកែខាងអ្វីសោះហើយ »



និយាយដល់ត្រឹមនេះ ពួកគាត់ក៏ជិះមកដល់កន្លែង ដែលលោកគ្រូសុខចូលចិត្តមកអង្គុយលំហែកាយលេង។
លោកគ្រូសុខក៏បាននិយាយ « ឱ្យតែលោកគ្រូមានពេលទំនេរ លោកគ្រូចូលចិត្តមកទីនេះលេងហើយ »។
មករាលាន់មាត់ « ខ្ញុំស្រេកទឹកណាស់ »
រតនាក៏ឆ្លើយ « អូ! អត់បានទេ » រតនានិយាយទាំងយំ « យើងភ្លេចយកទឹកមកបាត់ទៅហើយ។ តើគួរធ្វើយ៉ាងណាទៅ? »



មករាក៏មានយោបល់ « ប្រហែលជាពួកយើងអាចបេះផ្លែដូងនៅដើមនេះបាន។ តើធ្វើយ៉ាងណាទើបបេះផ្លែដូងបានទៅណ៎? »

អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C




រតនារាប់ផ្លែដូងទាំងអស់ ដែលនៅលើដើមដូងនោះ។ នាងក៏បូកដកឃើញថា បើពួកគេអាចបេះដល់
ពួកគេនឹងបានផ្លែដូងម្នាក់មួយ ហើយនៅសល់ដូងពីរផ្លែទៀតផង តែបូកដកបែបនេះ មិនអាចជួយឱ្យពួកគាត់បេះផ្លែដូងបាននោះទេ។




មករាក៏និយាយ « ខ្ញុំអាចប្រកបពាក្យផ្លែដូងបានយ៉ាងល្អ។ ផ ជើង ល ដាក់ស្រៈ ែ ផ្លែ ដ ដាក់ស្រៈូ នឹង ង ខ្ញុំអានថាផ្លែដូង » តែការដែលមករាចេះប្រកបពាក្យផ្លែដូងដូចនេះ មិនអាចជួយឱ្យពួកគាត់បេះផ្លែដូងបាន សូម្បីតែមួយផ្លែឡើយ។

អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C



យ៉ោកខំឈរចង្អើត លើកដៃឈោងទៅលើ តែទោះជាគាត់អាចលើកដៃបានខ្ពស់ប៉ុណ្ណាក៏ដោយ
ក៏មិនខ្ពស់ដល់ថ្នាក់អាចបេះផ្លែដូងបានដែរ។



លោកគ្រូសុខឱនក្បាលចុះ ហើយរត់សម្រុកទៅបុកដើមដូងពេញមួយទំហឹង។

គាត់គិតថា ធ្វើយ៉ាងនេះអាចធ្វើឱ្យផ្លែដូងរង្គើធ្លាក់ចុះក្រោម។ តែចុងក្រោយ បែរជាគ្មានផ្លែដូងណាធ្លាក់មក សូម្បីតែមួយផ្លែសោះ។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C




ស្រាប់តែពេលនោះ មានដូងមួយផ្លែធ្លាក់មកក្អុក នៅជិតរតនាតែម្តង  ធ្វើឱ្យពួកគាត់លោតឆ្ងាក់ខ្លួនគ្រប់ៗគ្នា។

« ក្អុក! » ដូងមួយផ្លែទៀតធ្លាក់មកជិតមករាហើយ!

« ក្អុកៗ! »

« តើមានរឿងអ្វីកើតឡើងហ្នឹង? »



ពួកគេក៏នាំគ្នាងើយមើលទៅលើទាំងអស់គ្នា ឃើញខេទីនៅលើដើមដូង កំពុងបេះផ្លែដូងជិតបានមួយផ្លែទៀតហើយ!

« ក្អក! »

តោះទះដៃឱ្យខេទីទាំងអស់គ្នា ព្រោះគាត់បានជួយសង្គ្រោះអ្នកទាំងអស់គ្នា ពីការស្រេកទឹកនៅគ្រានេះបានហើយ។



រតនាក៏និយាយ « ឃើញអត់ខេទី តាមពិតអ្នកពូកែទេតើ គឺពូកែខាងឡើងដើមឈើនោះអី »
មករាក៏និយាយបន្ត « មនុស្សម្នាក់ៗសុទ្ធតែពូកែមួយរឿងផ្សេងៗពីគ្នា »៕